**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខៈ ០០៧៧.សរ.ណ.ស.ប.ស្ល

ថ្ងៃចន្ទ ១១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៩

# សេចក្ដីណែនាំ
## ស្ដីពី
## ការគ្រប់គ្រង និងប្រើប្រាស់អាវុធនៅតាមតំបន់ការពារធម្មជាតិ

ដើម្បីគ្រប់គ្រងអាវុធគ្រាប់រំសេវនៅតាមតំបន់ការពារធម្មជាតិ ស្របតាមច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ ច្បាប់ស្ដីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ និងក្រមព្រហ្មទណ្ឌឱ្យមានប្រសិទ្ធភាព ក្រសួងបរិស្ថានសូមធ្វើការណែនាំ និងដាក់ចេញនូវបទបញ្ជាដូចខាងក្រោម៖

១- ត្រូវរៀបចំឃ្លាំង និងមានធ្វើរដាក់អាវុធនៅទីតាំងដែលមានសុវត្ថិភាព និងឱ្យបានត្រឹមត្រូវល្អតាមលក្ខណៈបច្ចេកទេស នៃការថែរក្សាអាវុធ ព្រមទាំងមានអ្នកគ្រប់គ្រងឃ្លាំង និងមានបញ្ជីចេញចូលច្បាស់លាស់។

២- អាចប្រើប្រាស់អាវុធបានតែក្នុងពេលចុះបំពេញបេសកកម្មល្បាត ទប់ស្កាត់ បង្ក្រាបបទល្មើសធនធានធម្មជាតិគ្រប់រូបភាពក្នុងតំបន់ការពារធម្មជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយភ្ជាប់ជាមួយនូវលិខិតបញ្ជាបេសកកម្មនិងប័ណ្ណសម្គាល់អាវុធឱ្យបានត្រឹមត្រូវ។

៣- ក្នុងពេលបំពេញបេសកកម្ម ហាមដាច់ខាតការបាញ់បោះ លើកលែងក្នុងករណីពិសេសដែលត្រូវការពារខ្លួននូវគ្រោះថ្នាក់ចំពោះមុខ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ។

៤- ក្រោយពីបញ្ចប់បេសកកម្ម ត្រូវប្រមូលអាវុធទាំងអស់លាងសម្អាត និងរក្សាទុកក្នុងឃ្លាំងវិញលើធ្នើរឱ្យបានត្រឹមត្រូវដោយដោះគ្រាប់ចេញ និងចាក់សោឱ្យបានគត់មត់ល្អ មានសុវត្ថិភាព និងមានការកត់ត្រាបញ្ជីចេញចូលឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។

៥- មានតែប្រធានអង្គភាព ឬប្រធានស្នាក់ការតែប៉ុណ្ណោះ ដែលមានសិទ្ធិកាន់កាប់ និងប្រើប្រាស់សោឃ្លាំងអាវុធ។

៦- ករណីបាត់អាវុធ ឬប័ណ្ណសម្គាល់អាវុធ ឬគ្រាប់រំសេវ ដែលបាននិងកំពុងកាន់កាប់ប្រើប្រាស់ត្រូវរាយការណ៍មិនលើសពីម្ភៃបួន(២៤)ម៉ោងក្រោយពេលដឹងថាបាត់ ដល់សមត្ថកិច្ចនគរបាលរដ្ឋបាលឃុំ សង្កាត់ ឬកងរាជអាវុធហត្ថ ឬបណ្ដាភូមិភាគ ឬតំបន់ប្រតិបត្តិការសឹករងនៅនឹងកន្លែងដែលជិតបំផុត ហើយត្រូវមានសាក្សីដឹងឮម្នាក់ ឬពីរនាក់ទៅជាមួយផងនៅពេលរាយការណ៍។

៧- របាយការណ៍ស្ដីពីការបាត់អាវុធ ឬប័ណ្ណសម្គាល់អាវុធ ឬគ្រាប់រំសេវ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយបញ្ជាក់លម្អិតពី ប្រភេទអាវុធ លេខប័ណ្ណសម្គាល់អាវុធ និងចំនួនគ្រាប់រំសេវ ព្រមទាំងមូលហេតុ និងកាលៈទេសៈនៃការបាត់នោះ។

អាគារមរតកតេជោ ដីឡូលេខ503 ផ្លូវកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

៨- ប្រធានមន្ទីរបរិស្ថាន និងជាប្រធានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិរាជធានីខេត្ត ដែលបានទទួលអាវុធប្រភេទ CKC ត្រូវស្នើសុំគ្រាប់ទ្រឹកជាយោធាបាឡូនៅតាមបណ្ដាភូមិភាគ ដើម្បីហ្វឹកហ្វឺនបណ្ដុះបណ្ដាល ដល់ប្រធានមន្ទីរបរិស្ថានខេត្ត និងមន្ត្រីឧទ្យានុរក្សក្នុងការប្រើប្រាស់ថែទាំ និងគ្រប់គ្រងអាវុធ ប្រភេទ CKC។

៩- មន្ត្រីឧទ្យានុរក្សប្រចាំការតាមតំបន់ការពារធម្មជាតិ ដែលមានសិទ្ធិប្រើប្រាស់អាវុធទាំងអស់ត្រូវបានហាមដាច់ខាតនូវរាល់ការលក់ ការផ្ទេរ ឬឱ្យខ្ចីអាវុធ គ្រាប់រំសេវទៅឱ្យបុគ្គលណាមួយ ទោះក្នុងករណីណាក៏ដោយ។

១០-ប្រធានការិយាល័យតាមតំបន់ការពារធម្មជាតិនីមួយៗ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់អាវុធ និងគ្រាប់រំសេវក្នុងតំបន់ការពារធម្មជាតិរបស់ខ្លួនឱ្យបានហ្មត់ចត់។

១១-ប្រធានមន្ទីរបរិស្ថាន និងជាប្រធានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិរាជធានី ខេត្ត ដែលមានតំបន់ការពារធម្មជាតិ ត្រូវរាយការណ៍ពីបច្ចុប្បន្នភាពនៃការគ្រប់គ្រងប្រើប្រាស់អាវុធជារៀងរាល់៣ខែម្ដង មកអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដើម្បីបូកសរុបជូនក្រសួងបរិស្ថាន និងសម្រាប់រាយការណ៍ជូនអគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស នៃក្រសួងការពារជាតិ។

ទទួលបានសេចក្ដីណែនាំនេះ មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ក្នុងករណីអនុវត្តផ្ទុយពីការណែនាំ និងបទបញ្ជាខាងលើ មន្ត្រីដែលមានសិទ្ធិប្រើប្រាស់អាវុធ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

រដ្ឋមន្ត្រី

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងបរិស្ថាន

សាយ សំអាល់

**ចម្លងជូន៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងយុត្តិធម៌
- រដ្ឋបាលខេត្ត ក្រុងពាក់ព័ន្ធ
- ឯកសារ កាលប្បវត្តិ